ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**តាងនាមប្រជារាស្ត្រខ្មែរ**

សំណុំរឿងរដ្ឋប្បវេណី

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ៖ ០០៦/០៨-១-២០១៣ បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នាថ្ងៃទី ១២.៣.២០១៣

សាលដីកា

**ក្រុមប្រឹក្សាជំនុំជំរះ**

លេខ៖ ០៧ក្រIVអ/១២.៣.២០១៣ លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រម

លោក [redacted] ជាចៅក្រម

**តំណាងមហាអយ្យការ**

លោក[redacted]

**ក្រឡាបញ្ជី**

លោកស្រី[redacted]

-ដើមចោទ ឈ្មោះ [redacted] ណារឿន ភេទប្រុស អាយុ៥៧ឆ្នាំ ជាតិខ្មែរ មុខរបរគ្មាន ទីលំនៅសព្វថ្ងៃ ផ្ទះលេខ០៨E០ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] ទីវ (ស) ម្តាយឈ្មោះ[redacted]ណាយ (ស) ប្រពន្ធឈ្មោះ[redacted] ស្រីវ័ត្ន មានកូន០២នាក់ ។

-ចុងចម្លើយ ឈ្មោះ [redacted] ស្រីវ័ត្ន ភេទស្រី អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ០៨E០ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]ន (ស) ម្តាយឈ្មោះ[redacted] ទូច (រ) ប្តីឈ្មោះ [redacted] ណារឿន មានកូន២នាក់ ។

**កម្មវត្ថុបណ្តឹង ៖**

កម្មវត្ថុៈ

-ឈប់រស់នៅជាអនីតិសង្វាស

-បែងចែកទ្រព្យសម្បត្តិរួម

-គ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក

-គ្រប់គ្រងកូន

**អង្គហេតុ និងចំណុចវិវាទ ៖**

-តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ[redacted]ណារឿន ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ បានប្តឹងថា ខ្លួន និងឈ្មោះ [redacted] ស្រីវ័ត្ន បានរួមរស់នៅជាមួយគ្នាបែបអនីតិសង្វាសជាប្តី-





Scanned with CamScanner

ប្រពន្ធលួចលាក់ ពុំបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ និងពុំមានសំបុត្រអាពាហ៍ពិពាហ៍ឡើយ ហើយការរួមរស់នៅជាមួយគ្នានេះ មិនបានប៉ុន្មានគឺនៅថ្ងៃទី ២៥-៥-២០០៧ ក៏មានការទាស់ទែងគ្នា និងលែងលះគ្នាម្តងរួចមកហើយ ដោយឈ្មោះ [redacted] ស្រីវ័ត្ន នេះបានទាមទារជាថ្នូរនូវទឹកប្រាក់ចំនួន ២០០០ដុល្លារ (ពីរពាន់ដុល្លារអាមេរិក) ដោយសន្យានឹងឈប់រួមរស់នៅជាមួយគ្នាទៀតហើយ ។ ដូចមានកិច្ចសន្យាយល់ព្រមលែងលះ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០០៧ ។ តែក្រោយមករយៈពេលមួយខែ ឈ្មោះ [redacted] ស្រីវ័ត្ន នេះបានត្រឡប់មកសុំរួមរស់នៅជាមួយខ្ញុំបាទជាប្តីម្តងទៀត ដោយសន្យាថា និងឈប់ប្រព្រឹត្តអំពើអបាយមុខផ្សេងៗដូចជាដើរលេងល្បែងស៊ីសង ប្រព្រឹត្តអំពើអ្វីៗតាមតែចិត្តខ្លួនឯង និងមានអត្តចរិតរឹងរូស មិនស្តាប់បង្គាប់ប្តីជាដើម ។ ឃើញដូច្នេះខ្ញុំបាទក៏បានយល់ព្រមអោយឈ្មោះ [redacted] ស្រីវ័ត្ន រស់នៅជាមួយខ្ញុំបាទម្តងទៀត ក្រែងឈ្មោះនេះមានការកែប្រែអត្តចរិតថ្មី ។

ប៉ុន្តែមកដល់ឆ្នាំ២០០៩ ពេលដែលខ្ញុំបាទ ត្រូវចូលនិវត្តន៍ត្រូវអស់ការងារធ្វើពុំអាចមានលទ្ធភាពចិញ្ចឹមអោយបានគ្រប់គ្រាន់ដូចពេលមុន ស្រាប់តែឈ្មោះ [redacted] ស្រីវ័ត្ន នេះចាប់ផ្តើមគំនិតនិងអត្តចរិកដូចមុនដដែល និងរករឿងឈ្លោះប្រកែកគ្នា ពុំចេះចប់ពុំចេះហើយឡើយ ។

ដូច្នេះខ្ញុំបាទពុំអាចរស់នៅដោយការរករឿងឈ្លោះប្រកែក ធ្វើទុក្ខបុកម្នេញគ្រប់ពេលជាមួយឈ្មោះ [redacted] ស្រីវ័ត្ន នេះតទៅទៀតឡើយ ហើយសុំប្តឹងលែងលះឈប់រស់នៅបែបអនីតិសង្វាស ជាមួយឈ្មោះនេះតទៅទៀតហើយ ។

ការអះអាងរបស់គូភាគី ៖

-ដើមចោទឈ្មោះ [redacted] ណារឿន បានធ្វើសេចក្តីថ្លែងហេតុថា ៖ ចំពោះផ្ទះលេខ០៨E0 ផ្លូវលំ ភូមិព្រៃព្រីខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ខ្ញុំទិញនៅឆ្នាំ២០០៩ ផ្ទះនេះខ្ញុំដាក់តែឈ្មោះ ខ្ញុំម្នាក់ឯងទេ ព្រោះខ្ញុំទិញដោយលុយផ្ទាល់ខ្លួនខ្ញុំក្នុងតម្លៃ២៤០០០$ លុយនេះខ្ញុំបានពីសន្សំជាយូរយារណាស់មកហើយ និងខ្វះខាតមួយចំនួនខ្ញុំខ្ចីបងប្អូនខ្ញុំដើម្បីទិញ ។ ខ្ញុំបាននាងជាប្រពន្ធនៅពេលខ្ញុំធ្វើការនៅមន្ទីរសុរិយោដីក្រុងភ្នំពេញ ខ្ញុំរៀបការជាមួយចាន់ស្រីវ័ត្ន អត់បានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ព្រោះកាលនោះខ្ញុំមានប្រពន្ធមិនទាន់លែងលះគ្នាចប់ ព្រោះកំពុងលែងលះនៅតុលាការ ។ សព្វថ្ងៃនេះខ្ញុំស្រឡាញ់កូនខ្ញុំណាស់ ខ្ញុំចូលនិវត្តន៍ហើយ ខ្ញុំបានប្រាក់ខែចំនួន ៩៤៥៦០រៀល ក្នុងមួយខែ ខ្ញុំគ្មានចំណូលផ្សេងទៀតទេ ទ្រព្យសម្បត្តិខ្ញុំលក់ប្រមូលទិញផ្ទះនេះអស់ហើយ ។

សំណូមពរ ៖ សុំលោកតុលាការ មេត្តាតម្កល់សាលក្រមរដ្ឋប្បវេណីលេខៈ៤៥ (ឃ) ចុះថ្ងៃ ៣០.កក្កដា.២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកនៅដដែល ។

-ចុងចម្លើយ ឈ្មោះ [redacted] ស្រីវ័ត្ន បានធ្វើសេចក្តីថ្លែងហេតុថា ៖ នាងខ្ញុំប្តឹងឧទ្ធរណ៍មកនេះ ព្រោះខ្ញុំមិនសុខចិត្តចំពោះអាហារកិច្ចចិញ្ចឹមកូននិងគ្រង់ទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទផ្ទះលេខ០៨ E0 ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នាងខ្ញុំសុំផ្តាច់ប្រាក់អាហារកិច្ចចិញ្ចឹមកូនពី [redacted] ណារឿន ទាំងអស់តែម្តង ព្រោះកន្លងមកគាត់ចេញពីផ្ទះ២-៣មកឆ្នាំហើយ គាត់មិនឲ្យលុយកូនចាយសូម្បីតែ៥០០០៛ ។ នាងខ្ញុំបានរៀបការជាមួយ [redacted] ណារឿន នៅឆ្នាំ២០០៤ ពេលការហើយទាំងពីរនាក់ ប្តីប្រពន្ធខ្ញុំនេះ អត់មានទ្រព្យ



Scanned with CamScanner

សម្បត្តិរៀមទាំងអស់ អោយខ្ញុំបានទៅធ្វើការនៅរោងចក្រ និងរកស៊ីកប់លុយចងការប្រាក់ឲ្យអ្នកនៅក្នុងរោងចក្ររហូតដល់ឆ្នាំ២០០៥ ក៏បានកូន២នាក់ក៏មានផ្ទះ ។ ក្រោយមកគាត់បានក្បត់ខ្ញុំលួចទិញផ្ទះលេខ ០៨ E0 ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ នៅឆ្នាំ២០០៥ ដោយដាក់តែឈ្មោះ គាត់ម្នាក់ឯង ហើយគាត់ប្រាប់ខ្ញុំថាកុំភ័យបងទិញផ្ទះនេះដើម្បីអនាគតកូនយើង ។

សំណូមពរៈ សុំលោកតុលាការបែងចែកផ្ទះលេខ ០៨ E0 ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាពីរចំណែកស្មើគ្នា និងប្រាក់អាហារកិច្ចចិញ្ចឹមកូន១ខែ១០ម៉ឺន ដោយសុំយកផ្ទាល់ទាំងអស់តែម្តង ។

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានស្តាប់របាយការណ៍ និងការសួរដេញដោលមក ឃើញថារឿងក្តីនេះមានការពាក់ព័ន្ធដល់ផលប្រយោជន៍របស់គូភាគីទាំងសងខាង តំណាងមហាអយ្យការយល់ឃើញថា ការសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញត្រង់ចំណុចអាហារកិច្ចចិញ្ចឹមកូននេះគឺមានលក្ខណៈសមហេតុផលហើយ ព្រោះឪពុកពុំមានប្រាក់ចំណូល ហើយប្រាក់ខែចូលនិវត្តន៍បានតិចតួច គឺសុំឲ្យឪពុករបស់ក្មេងបង់ប្រាក់អាហារកិច្ចនេះអោយបានទៀងទាត់រាល់ខែចំពោះទ្រព្យសម្បត្តិរួម សុំក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

## <u>សំអាងហេតុ</u> ៖

-យល់ឃើញថា ៖

១.បណ្តឹងឧទ្ធរណ៍ លេខ ២៦០ ចុះថ្ងៃ២៧.សីហា.២០១២ របស់ឈ្មោះ [redacted] ស្រីវ័ន្ត ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

២.ចុងចម្លើយប្តឹងឧទ្ធរណ៍ពីសាលក្រមរដ្ឋប្បវេណីលេខ ៤៥ "យ" ចុះថ្ងៃ៣០.៧.២០១២ ត្រង់ចំណុចទី២ ត្រង់អាហារកិច្ចចិញ្ចឹមកូន ត្រង់ចំណុចទី៤ ក ត្រង់ទ្រព្យដោយឡែករបស់ដើមចោទ គឺផ្ទះលេខ០៨ E0 ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ គប្បីក្រុមប្រឹក្សា សាលាឧទ្ធរណ៍ពិចារណាឡើងវិញ ។

៣.តាមសៀវភៅនិវត្តជន របស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា បញ្ជាក់ថា ឈ្មោះ [redacted] ណារឿន បានចូលនិវត្តន៍ថ្ងៃ១.ឧសភា.២០០៩ មានប្រាក់សោធននិវត្តប្រចាំខែចំនួន ៩៤៥៦០រៀល (ឯ.១៩/១១) ។ ដូចនេះឈ្មោះ [redacted] ណារឿន ពុំមានលទ្ធភាពផ្តល់អាហារកិច្ចចិញ្ចឹមកូន២នាក់ក្នុង១ខែ ៥០ម៉ឺនរៀល ដូចការទាមទាររបស់ចុងចម្លើយនោះទេ ។ គប្បីតម្កល់ចំណុចទី២ នៃសេចក្តីសម្រេចក្នុងសាលក្រមលេខ ៤៥ "យ" ចុះថ្ងៃ៣០.៧.២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកដដែល ។

៤.តាមពាក្យបណ្តឹងចុះថ្ងៃ ២៦ កក្កដា ២០១១ របស់ឈ្មោះ [redacted] ណារឿន (ឯ.៥) បញ្ជាក់ថា ខ្លួននិង [redacted] ស្រីវ័ន្ត រួមរស់នៅជាមួយគ្នាបែបអនីតិសង្វាស់ជាប្តីប្រពន្ធលួចលាក់ ពុំបានរៀបអាពាហ៍ពិពាហ៍តាមច្បាប់ទេ ។ ឃើញថា ការអះអាងនេះផ្ទុយពីលិខិតបញ្ជាក់ចុះថ្ងៃ ៨.៩.២០១១ របស់មេភូមិត្រាវអែម ឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ ផ្ទុយពីឯកសាររូបថត ២៧សន្លឹក ដែលបញ្ជាក់ថាបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី និងមានសៀវភៅ

គ្រួសារ លេខ ០៥ គ្រក.២៨៦៣៥ (ឯ.៧) បញ្ជាក់ថា ឈ្មោះ [redacted] ណារឿន ជាមេគ្រួសារ និងឈ្មោះ[redacted] ស្រីវ័ន្ត ជាប្រពន្ធ គ្រាន់តែពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ប៉ុណ្ណោះ ។

ដើមចោទ និងចុងចម្លើយបានព្រមព្រៀងលែងលះគ្នាកាលពីថ្ងៃ២៥ ឧសភា ២០០៧ ហើយ មួយខែក្រោយមកឈ្មោះ[redacted] ស្រីវ័ន្ត បានត្រឡប់មកសុំរួមរស់ជាមួយគ្នាតទៅទៀតរហូតដល់មានបណ្តឹងសុំឈប់រស់នៅជាអនីតិសង្វាស ចុះថ្ងៃ២៦.៧.២០១១ របស់ដើមចោទ ។ ដូចនេះផ្ទះល្វែង លេខ ៨E០ ទំហំ ១៦ម×៤ម ស្ថិតនៅ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ដែលតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី-ផ្ទះ ចុះថ្ងៃ១.៦.២០០៩ (ឯ.១២) មានឈ្មោះ [redacted] ណារឿន តែម្នាក់ឯងក៏ដោយ តែទិញក្នុងពេលរួមរស់នៅជាមួយគ្នា ចាត់ទុកជាទ្រព្យរួមរបស់ដើមចោទ និងចុងចម្លើយ ។ គប្បីបែងចែកតាមច្បាប់ ។

៥.សាលក្រមរដ្ឋប្បវេណី លេខ ៤៥ "ឃ" ចុះថ្ងៃ៣០ កក្កដា ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី២ មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុច ៤-ក ត្រូវកែប្រែតាមការយល់ឃើញខាងលើ ។

**ហេតុដូចនេះ វិនិច្ឆ័យសេចក្តី**

១.ច្រានចោលបណ្តឹងឧទ្ធរណ៍ លេខ ២៦០ ចុះថ្ងៃ២៧ សីហា ២០១២ របស់ឈ្មោះ [redacted] ស្រីវ័ន្ត ត្រង់ចំណុចទី២ នៃសេចក្តីសម្រេច ។

២.តម្កល់ចំណុចទី២ នៃសាលក្រមលេខ ៤៥ "ឃ" ចុះថ្ងៃ៣០ កក្កដា ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣.លុបចោលចំណុចទី៤-ក នៃសេចក្តីសម្រេចសាលក្រមលេខ ៤៥ "ឃ" ចុះថ្ងៃ៣០ កក្កដា ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤.បែងចែកជាពីរចំណែក ផ្ទះលេខ ០៨E០ ផ្លូវលំ ភូមិព្រៃព្រីងខាងជើង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ តាមតម្លៃទីផ្សារអោយឈ្មោះ[redacted] ណារឿន មួយចំណែក និងឈ្មោះ [redacted] ស្រីវ័ន្ត មួយចំណែកស្មើគ្នា ។ ចំណុចផ្សេងទៀតនៃសាលក្រមតម្កល់ទុកជាបានការដដែល ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុកដើមចោទ ។

៦.សាលដីកានេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈ បើកសិទ្ធិប្តឹងសាទុក្ខរយៈពេល១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| --- | --- | --- |

ហត្ថលេខា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
សាលាឧទ្ធរណ៍ ថ្ងៃទី25 ខែ [illegible].....ឆ្នាំ២០១៣
ក្រឡាបញ្ជី

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជំរះ

[redacted]

៣៤៩

[redacted]



Scanned with CamScanner